ភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៩៣

**គោរពជូនមក**

លោកនាយកផ្នែកវិទ្យុផ្សាយសម្លេងអ៊ុន គាក់

<u>កម្មវត្ថុ</u>៖ សូមមេត្តាផ្សាយសម្លេងនូវបទកំណាព្យពាក្យប្រាំពីរដែលមានចំណងជើងថា “សិទ្ធិមានត្រឹមណា” ដោយអនុគ្រោះ។

ហត្ថលេខា

សេង យាន

**<u>សិទ្ធិមានត្រឹមណា</u>**

1. ឱសិទ្ធិសេរីថ្លៃម្ល៉េះទេ ទាំងខ្ញុំទាំងគេចង់បានណាស់
មានសិទ្ធិសេរីកើតប្រាជ្ញាច្បាស់ ហ៊ានថាហ៊ានដាស់សតិផងគ្នា។

2. សិទ្ធិសេរីជាអាវុធពិសិដ្ឋ បើចេះប្រើពិតទើបល្អជា
តែចេះស្ទើរៗអាចក្លាយជា អាវុធប្រហារគ្មានរើសមុខ។

3. ឱបងប្អូនអើយសូមជួយគិត ខ្ញុំរំលឹកគំនិតមកដាក់ទុក
ព្រោះចង់ឲ្យខ្មែរយើងបានសុខ ពេលសិទ្ធិពេញស្រុកត្រូវចេះប្រើ។

4. ប្រើសិទ្ធិបានល្អរួចផុតទុក្ខ បងប្អូនអ្នកស្រុកកោតសរសើរ
ស្រឡាញ់រាប់រករួមដំណើរ រាក់ទាក់ឈានដើរមិនមានភ័យ។

5. ចេះប្រើសិទ្ធិឥតរំលោភគេ ព្រោះយល់សិទ្ធិគេជាមនុស្សថ្លៃ
មនុស្សដូចគ្នាទេចរណៃ ត្រូវចេះលកលៃយល់គេឯង។

6. សិទ្ធិប្រើសម្លេងហ៊ោរសប្បាយ រីករាយក្អាកក្អាយលាន់បែកផ្សែង
តែសុំគិតផងណាព្រះស្តែង ត្រូវចេះរអែងអ្នកជិតខាង។

7. ស្រែកហ៊ោរមានពេលម៉ោងកំណត់ កុំក្បត់យកសិទ្ធិខ្លួនមកអាង
សិទ្ធិគេមានដែរកុំប្រងាង នាំគ្នាសាងសុខទើបប្រពៃ។

8. សិទ្ធិចាក់មេក្រូឮលាន់មេឃ បានលុយឥតខ្លាចពីណាក្ស័យ

ខំបើកឲ្យញអ្នកទិញថ្លៃ ម្ចាស់ថោកចង្រៃមិនស្គាល់សិទ្ធិ។

9. រឿងនេះម្ចាស់បុណ្យម្ចាស់មេក្រូ គួរតែគិតគូរឲ្យបានល្អិត
ពេលណាគួរញពេលណាបិទ ឲ្យញល្មមពិតផុតគេជេរ។

10. សិទ្ធិប្រើផ្លូវថ្នល់សាធារណៈ ត្រូវចេះច្បាប់ដាក់កុំធ្វេសទ្វេ
គ្មានប័ណ្ណបើកបរប្រថុយដែរ កើតទុក្ខឥតល្ហែពេលគ្រោះថ្នាក់។

11. ទុក្ខមួយព្រួយកាយឈឺខ្លោចផ្សា អាចក្លាយពិការដល់មរណៈ
ទុក្ខមួយព្រួយព្រោះបង់ទ្រព្យប្រាក់ ក្តុកក្តួលអួលអាក់ធ្លាក់ក្របាន។

12. អ្នកដើរអ្នកជិះកង់ម៉ូតូ អ្នកជាក់ស៊ីក្លូអ្នកបើកឡាន
សិទ្ធិខ្លួនត្រឹមណាកុំក្លាហាន ក្រែងឆាប់ចាកឋានខានសប្បាយ។

13. សិទ្ធិចិញ្ចឹមសត្វប្រាថ្នាសាច់ មាន់ជ្រូកគោអាចម៍ឈ្លូសកកាយ
ស៊ីដំណាំផងហិនគួរស្តាយ បែរហ៊ានមាក់ងាយបន្ទោសថា។

14. ម្តេចមិនដេញផងសត្វដឹងអ្វី ចំជាអប្រិយ៍ពោលមុសា
ខ្លួនខុសជ្រងោបែរតវ៉ា ស្តីថារំលោភសិទ្ធិគេផង។

15. សត្វមិនចេះដឹងសិទ្ធិអ្វីទេ ប៉ុន្តែមាសមេកុំរំលង
រំលោភគេពេកនាំសោះហ្មង គេដាំប៉ុនប៉ងបានផល្លា។

16. ប្រយោជន៍ចង់បានរៀងៗខ្លួន ប៉ុន្តែមាសស្ងួនត្រូវយល់គ្នា
ត្រូវស្គាល់ព្រំដែនសិទ្ធិត្រឹមណា កុំចេះតែថាឥតមានខ្មាស់។

17. សិទ្ធិចូលធ្វើការបំរើជាតិ តែកុំប្រើស្នៀតបែបផ្តេសផ្តាស
លោភលន់កេងកិបឆាប់រហ័ស ស្គារដើមក្រែលក្រាសឲ្យជាតិក្រ។

18. សិទ្ធិនេះមិនល្អទេណាថ្លៃ ចង់មានទាំងថ្ងៃម្នុសកុះករ

គេចាំតែមើលកុំរីរ		តែហ៊ានលបលលង់ពុំខាន។

19. សិទ្ធិចូលសាងផ្នួសសាងសីលទាន	កើតបានជាស្ពានឆ្លងទៅឋាន
សួគ៌សុខគ្មានទុក្ខហៅនិព្វាន		សិទ្ធិចេះព្រានលានកោតគោរព។

20. សិទ្ធិកាប់គាស់ដីស្រែចំការ	បង្កើតផលល្អចិញ្ចឹមគ្រប់
ម្នុសម្នាខេត្តក្រុងអរចំប្រប់		លើកម្រាមដៃដប់សូមជូនពរ។

21. សិទ្ធិឈ្មួញជួញប្រែតាមទីផ្សារ	លក់ដូរភ័ស្តុភារហុរហៀរគរ
ចិត្តមិនសូវល្អច្រើនភូតភរ		ល្មមអាជ្ញាធរមើលគាត់ផង។

22. កុំបើកសិទ្ធិកាត់ហួសព្រំដែន	ព្រោះតែសូកសែនហ៊ានកន្លង
រង្វាស់វាល់ថ្លឹងខុសទំនង		សិទ្ធិនេះប្អូនបងឆាប់ទប់ទល់។

23. សិទ្ធិបែបរកស៊ីមិនមានដើម		ឆក់ប្លន់សំបើមឥតគិតខ្វល់
បាញ់កាប់សម្លាប់ឥតយោគយល់	ហួសព្រំប្រទល់សិទ្ធិហើយថ្លៃ។

24. អ្វីទៅសិទ្ធិអ្នកអាចធ្វើបាន		ត្រង់កុំបំពានអ្នកដទៃ
ឲ្យគេកើតទុក្ខឈឺផ្សាក្រៃ		សិទ្ធិនេះមានថ្ងៃជាប់ចំណង។

25. សិទ្ធិសារពត៌មានហ៊ានសរសេរ	អស់ពួកវាចវេរស្អប់កន្លង
គ្មានលាក់គ្មានបាំងយោគយល់ផង	រាស្ត្រអរកន្លងមានសិទ្ធិនេះ។

26 សិទ្ធិចេះជួយជាភ្នែកច្រមុះ		រាំងស្កាត់កំហុសពួកពុកច្រេះ
ជួយផ្តល់យោបល់សាងប្រទេស		សិទ្ធិចេះល្អម្ល៉េះសូមសុខសាន្ត។

27. សិទ្ធិមនុស្សច្រើនណាស់រាប់មិនអស់	ខ្ញុំលើកចោះៗតាមលំអាន
ខុសឆ្គងម្តេចម្តាសូមសន្តាន		មេត្តាប្រោសប្រាណខ្លួនខ្ញុំផង។

Phnom Penh, 8 July 1993

To Director of UNTAC Radio

<u>Objective</u>: Please disseminate through your radio broadcasting a poem entitled “The Boundary of Our Rights”

Signed

Seng Yan

<u>The Boundary of Our Rights</u>

1. The rights of freedom are priceless
Everybody wants them
They help increase awareness
Which makes us brave to incite each other’s thought.

2. The rights of freedom are the weapon
Ideal for those who know how to use them
But if one does not know them well
These rights would become a weapon of destruction.

3. Fathers and brothers, please help me think
I recall some advice here for you to think of
And to help the Khmers live in happiness
[You] need to use the rights that you have.

4. If you use your rights well, you will escape from sadness
People will admire you
Love and want to live with you
Because when they move around, they have nothing to worry of.

5. If one uses the rights without abusing others
As [he or she] understands their human rights
And the rights as human beings
[He or she] would find a way to live with them well.

6. One has the rights of cheering, laughing,
Screaming, and joy
But one also needs to be aware of
The rights of your neighbors.

7. [You] can cheer at a certain time period
But do not overuse your own rights
Against other people’s
[You] will create happiness among one another.

8. An action of turning on a loudspeaker loudly

Without considering others' wellbeing
Due to an ill intention of showing off an expensive loudspeaker
This action will downgrade the owner as the one who does not know people's rights.

9. The owner of the loudspeaker or the ceremony
[You] should be more considerate
About the times [you] should and should not voice the loudspeaker
To avoid curses given to you by other people.

10. There are rights of using the public roads
Which [you] need to know them well
If [you] has no driving license but insist to drive
[You] will encounter numerous difficulties when having an accident.

11. [You] will have physical injuries
Which can lead to disabilities or even death
[You] will also loss your properties
And fall into poverty.

12. Among those who walk, cycle, drive a motorbike
Ride a tricycle, and drive a car
[You] should be aware of the boundary of your rights
To avoid an unexpected death.

13. There are rights of farming animals for meat
But when [your] chicken, pigs and cattle
destroy other people's paddy farms
[You] instead blame those farms' owners.

14. By accusing them of being careless
And insulting them as a failure
But it is you who commit the mistake
Of verbally abusing other people's rights.

15. Your animals do not know anything
But you should be more cautious
You should not abuse other people's property so often
Every farmer wants profits from their crops.

16. Everyone wants profits
But we should also be considerate
By understanding the boundary of our own rights
And using them without shame.

17. There are rights of serving the country
But [he or she] should not use those rights illicitly
By overusing them and committing corruption
This will drive the country into poverty.

18. These rights are not good
As one wants to get rich fast while many others
Are watching
If one dares to become rich this way, [he or she] will get into troubles.

19. There are rights of entering the monkhood
Which can be an ideal bridge
Toward heavenly happiness called nirvana
These rights can generate a wide respect from many others.

20. There are rights of clearing [your] paddy fields
To make way for farming all types of crops or animals
People from everywhere will appreciate [your] actions
By giving you a great esteem.

21. There are rights of selling
All types of products
But if one does not conduct the business ethically
[He or she] will be reported to the police.

22. One should not use [his or her] rights beyond the boundary
By committing a dishonesty
Of faking the units of measurement for weight
This action should be stopped.

23. Actions of conducting a business without using any initial cash
Such as stealing other people's money
Or killing without mercy
Are beyond the boundary of one's rights.

24. Being aware of your own rights
By avoiding any abuses of others'
But if you do by causing pain and sorrow to them
[You] will be arrested one day.

25. There are rights of freedom of press
Which the corrupt people do not like them
Because [these rights] help to disclose all kind of information
Which make the public grateful due to their existence.

26. There are rights of identifying
Any irregular actions of corrupt people
[There are] also rights of giving advice to the country's development
Which are ideal tools for happiness.

27. There are countless human rights
Which I have mentioned a few here
If I made any unintended mistakes
Please kindly forgive me.